ខេមបូចា CamboJA
សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association
(+855) 023 88 23 11
communications@camboja.net
www.camboja.net | www.cambojanews.com

# សេចក្ដីប្រកាសព័ត៌មាន

## ការសិក្សាថ្មីមួយរបស់ខេមបូចាបង្ហាញពីផលវិបាកនៃការគំរាមកំហែងលើសិទ្ធិឌីជីថល និង សេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអនឡាញនៅកម្ពុជា

***ភ្នំពេញ, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣៖*** *ការសិក្សាថ្មីមួយរបស់ខេមបូចារកឃើញថា អ្នកសារព័ត៌មាន និងពលរដ្ឋដែលសកម្មលើបណ្ដាញអ៊ីនធឺណិត មានការព្រួយបារម្ភទាក់ទងនឹងស្ថានភាពសេរីភាពអ៊ីនធឺណិត សិទ្ធិឌីជីថល និងសុវត្ថិភាពលើប្រព័ន្ធអនឡាញនៅកម្ពុជា។ បន្ថែមលើនេះ បុគ្គលមួយចំនួនបានបង្ហាញពីភាពភ័យខ្លាចចំពោះ ការគំរាមកំហែងដែលអាចប៉ះពាល់ដល់សុវត្ថិភាពផ្ទាល់ខ្លួន ដែលកើតចេញពីអ៊ីនធឺណិតទៀតផង។*

*ការសិក្សាស៊ីជម្រៅស្ដីពី* ***"ផលប៉ះពាល់នៃការរឹតត្បិតសិទ្ធិឌីជីថលលើសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត"*** *នេះពិនិត្យលើ ផលប៉ះពាល់នៃការរឹតត្បិតតាមអ៊ីនធឺណិតនៅកម្ពុជាមកលើអ្នកសារព័ត៌មាន និងពលរដ្ឋដែលសកម្មលើបណ្ដាញអ៊ីនធឺណិត។ ការសិក្សានេះមានគោលបំណងបង្ហាញពីបញ្ហាប្រឈមរបស់អ្នកសារព័ត៌មាន និងប្រជាពលរដ្ឋ ដែលសកម្មនៅលើប្រព័ន្ធអនឡាញ ដោយសារតែការកំហិតលើសិទ្ធិឌីជីថល។*

*គោលបំណងចម្បងនៃការសិក្សានេះមានបីចំណុចសំខាន់ៗ៖ ទីមួយ វិភាគ-ឥទ្ធិពលអវិជ្ជមាននៃការរឹតត្បិត មកលើសិទ្ធិឌីជីថល និងសេរីភាពសារព័ត៌មាន ជាពិសេសទាក់ទងនឹងសេរីភាពបញ្ចេញមតិសម្រាប់អ្នកសារព័ត៌មាន និងពលរដ្ឋសកម្មលើអ៊ីនធឺណិត។ ទីពីរ គឺដើម្បីស្វែងរក និងស្វែងយល់ពីទស្សនៈចម្រុះរបស់អ្នកសារព័ត៌មានឯករាជ្យ និងពលរដ្ឋសកម្មតាមអ៊ីនធឺណិតទាក់ទងនឹងផលប៉ះពាល់នៃការរឹតត្បិតសិទ្ធិឌីជីថល។ និងទីបី គឺដើម្បីផ្ដល់ឱ្យភាគីពាក់ព័ន្ធនូវការយល់ដឹងឲ្យបានទូលំទូលាយអំពីបញ្ហាទាំងនេះ ជាមួយនិងអនុសាសន៍គោលនយោបាយដើម្បីលើកកម្ពស់ស្ថានភាពសិទ្ធិឌីជីថលរបស់កម្ពុជា។*

ខេមបូចា សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association
(+855) 023 88 23 11
communications@camboja.net
www.camboja.net | www.cambojanews.com

**ចំណុចសំខាន់ៗពីការសិក្សារួមមាន៖**

**១. អ៊ីនធឺណិតជាអាវុធមុខពីរ៖** ខណៈអ៊ីនធឺណិតបានក្លាយជាផ្នែកសំខាន់មួយនៃជីវិតរស់នៅក្នុងប្រទេសកម្ពុជា ដែលជួយសម្រួលដល់ការធ្វើទំនាក់ទំនង ការផ្សព្វផ្សាយព័ត៌មាន និងទស្សនៈចម្រុះផ្សេងៗគ្នា ក្តីបារម្ភជុំវិញកំណើននៃការប្រើប្រាស់អ៊ីនធឺណិត និងការឃ្លាំមើលពីសំណាក់រដ្ឋាភិបាល ក៏កំពុងមានការកើនឡើងដែរ។

**២. ការយល់ឃើញថាខ្វះសេរីភាពអ៊ីនធឺណិត៖** អ្នកឆ្លើយសំណួរក្នុងការស្រាវជ្រាវបានសម្តែងការព្រួយបារម្ភពីកង្វះ សេរីភាពអ៊ីនធឺណិត ដោយពួកគេយល់ថាមានការឃ្លាំមើលមកលើអ្នកសារព័ត៌មាន និងសកម្មជនពីសំណាក់ រដ្ឋាភិបាល និងក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISPs)។

**៣. ការព្រួយបារម្ភអំពីឧបករណ៍ច្បាប់៖** អ្នកឆ្លើយសំណួរភាគច្រើនបានសម្តែងក្តីព្រួយបារម្ភខ្លាចរដ្ឋាភិបាលប្រើប្រាស់ច្បាប់ជាឧបករណ៍ក្នុងការរឹតត្បិតសកម្មភាពលើបណ្តាញអ៊ីនធឺណិត ដោយបង្ហាញពីកង្វល់ជុំវិញផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន មកលើសេរីភាពនៃការបញ្ចេញមតិ។

**៤. ការរាំងដល់ការច្នៃប្រឌិត៖** ខណៈមានការទទួលស្គាល់ពីសក្តានុពលអ៊ីនធឺណិតសម្រាប់ការស្វែងយល់ពីទស្សនៈផ្សេងៗគ្នា អ្នកឆ្លើយសំណួរបានគូសបញ្ជាក់ពីរបៀបដែលការកំហិតនាពេលបច្ចុប្បន្ននេះបានរាំងដល់ការច្នៃប្រឌិត និងរឹតបន្តឹងការទទួលបានព័ត៌មានសំខាន់ៗសម្រាប់ប្រជាពលរដ្ឋ និងអ្នកបង្កើតគោលនយោបាយ។

**៥. ការគំរាមកំហែងផ្នែកសន្តិសុខ និងការរឹតត្បិតខ្លួនឯង៖** ការបារម្ភពីការគំរាមកំហែងមកលើសុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន ដែលកើតចេញពីសកម្មភាពលើប្រព័ន្ធអនឡាញ គឺជា